ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

លេខ : ៨៦៨៤ [illegible]

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០១៣

# សេចក្តីជូនដំណឹង

**អគ្គិសនីកម្ពុជា** មានកិត្តិយសសូមជម្រាបជូនលោក-លោកស្រីជាគ្រួសារក្រីក្រនៅតំបន់ជនបទ និងអ្នកផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទឲ្យបានជ្រាបថា៖ អគ្គិសនីកម្ពុជាតាមរយៈនាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ (ម.អ.ជ.) មាន "កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ" ក្នុងគោលបំណងជួយដល់គ្រួសារក្រីក្ររស់នៅតំបន់ជនបទ ដើម្បីឲ្យគ្រួសារទាំងនេះអាចទទួលបានការតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ដោយការផ្តល់ប្រាក់កម្ចីអនុគ្រោះគ្មានការប្រាក់ឲ្យគ្រួសារជនបទខ្ចីយកទៅ៖ បង់ថ្លៃភ្ជាប់ចរន្តឲ្យអ្នកផ្គត់ផ្គង់ បង់ថ្លៃប្រាក់កក់ឲ្យអ្នកផ្គត់ផ្គង់ ចំណាយលើការទិញនិងរាយខ្សែពីចំណុចភ្ជាប់ចរន្តមកដល់ផ្ទះរបស់ខ្លួន និងចំណាយលើការរៀបចំខ្សែបណ្តាញ និងឧបករណ៍អគ្គិសនីក្នុងផ្ទះ ដើម្បីតភ្ជាប់ចរន្តអគ្គិសនីចូលផ្ទះ។ ប្រាក់កម្ចីនេះនឹងទូទាត់តាមរយៈអ្នកផ្គត់ផ្គង់អគ្គិសនី ដែលជាអ្នកទទួលខុសត្រូវក្នុងការបង់សងត្រឡប់មក ម.អ.ជ. វិញ ពីការប្រមូលពីអ្នកខ្ចីដែលត្រូវបង់សងរៀងរាល់១ខែម្តងមក ម.អ.ជ. ក្នុងរយៈពេល ៣៦ខែ។ ចំនួនទឹកប្រាក់កម្ចីអនុគ្រោះនេះ គឺមិនលើសពី 480,000រៀល ក្នុង១គ្រួសារ។ កម្មវិធីនេះនឹងអនុវត្តន៍ក្នុងឆ្នាំ២០១៤ បន្តពីឆ្នាំ២០១៣ ជាបន្តទៀត ស្របតាមទំហំថវិកាដែល ម.អ.ជ. មាន។ លក្ខណៈវិនិច្ឆ័យសម្រាប់អនុវត្តន៍កម្មវិធីនេះ មានភ្ជាប់មកជាមួយ។

ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកលោក សាន វីរិយ៉ាន ទូរស័ព្ទលេខ 012 662 648 លោក គឹម ឬទ្ធី ទូរស័ព្ទលេខ 089 267 071 លោក ថាច់ កៀងមុនី ទូរស័ព្ទលេខ 016 988-685 ឬទាក់ទងផ្ទាល់មក ម.អ.ជ. ទូរស័ព្ទលេខ 023 997 600 ឬទូរសារលេខ 023 997 601 ឬអញ្ជើញមកទំនាក់ទំនងផ្ទាល់នៅអាគារលេខ២០៥ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

អាស្រ័យហេតុនេះ សូមលោក-លោកស្រីមេត្តាជ្រាបជាព័ត៌មាន និងជួយផ្សព្វផ្សាយបន្តស្តីពីកម្មវិធីនេះចាប់ពីថ្ងៃជូនដំណឹងនេះតទៅ សំដៅរួមចំណែកជំរុញការអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទឲ្យបានសម្រេចតាមគោលដៅអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទដែលបានកំណត់របស់រាជរដ្ឋាភិបាលកម្ពុជា។ ៚

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

**កែវ រតនៈ**

**ចម្លងជូន៖**

- អាជ្ញាធរអគ្គិសនីកម្ពុជា
- អគ្គនាយករងអគ្គិសនីកម្ពុជា
  ដើម្បី "ជូនជ្រាបជាព័ត៌មាន"
- ឯកសារ-កាលប្បវត្តិ